ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

# វេទិកាថ្នាក់តំបន់លើកទី១០សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី១០ នៅខេត្តកំពង់ស្ពឺ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលទើបទទួលស្គាល់ថ្មីៗនេះ នៃសំណុំរឿង០០២ ចំនួន ៣០០ នាក់ មកពីរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។ វេទិកាថ្នាក់តំបន់លើកនេះនឹងប្រព្រឹត្តទៅនៅ បន្ទប់ប្រជុំភោជនីយដ្ឋាន ទា ស៊ុយហេង ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ***នាថ្ងៃសុក្រ ទី ២៨ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង៧:៣០ ព្រឹក ដល់ ម៉ោង៣:៣០ រសៀល។*** *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានរក្សាជាសម្ងាត់)* ។

ដើមបណ្តឹងរដ្ឋប្បវេណីទាំង ៣០០នាក់ ដែលនឹងចូលរួមវេទិកាថ្នាក់តំបន់លើកនេះ ស្ថិតក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២ ដែលត្រូវបានអង្គបុរេជំនុំជម្រះ ទទួលស្គាល់ចំនួន ១.៧៤៥ នាក់ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១១ នេះ និងពេលក្រោយមកទៀត។ រហូតមកទល់ពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ សរុបទាំងអស់ មានចំនួន ៣.៨៦៧ នាក់។

វេទិកាថ្នាក់តំបន់នេះគឺជាសកម្មភាពដ៏សំខាន់មួយក្នុងចំណោមសកម្មភាពនានារបស់អង្គភាពគាំពារជនរងគ្រោះ ក្នុងការលើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយក្នុងដំណើរការរបស់ អ.វ.ត.ក ក្នុងឆ្នាំ ២០១១ និងដើម្បីពង្រឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណើរការច្បាប់សម្រាប់សំណុំរឿង០០២។ វេទិកាថ្នាក់តំបន់ នេះមានគោលបំណងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណី ៖

- ជួបជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិភាក្សាអំពីសិទ្ធិក្នុងការដាក់ពាក្យបណ្តឹង នីតិវិធីចូលរួមនៅក្នុងដំណើរការកាត់ក្តី ក៏ដូចជាប្រមូលគំនិតដែលពាក់ព័ន្ធនឹងសំណងដែលស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរៀបចំគម្រោងសំណងនិងស្នើទៅកាន់ អ.វ.ត.ក ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

- ជួបជាមួយមន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីស្វែងយល់ពីការវិវឌ្ឍថ្មីៗរបស់តុលាការ។
- ជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ដើម្បីចែករំលែកបទពិសោធន៍សម្រាប់សំណុំរឿង០០២។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖
អ៊ឹម សុភា, ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ
ទូរស័ព្ទចល័តៈ ០៧៧ ៧៧៧ ៣៦៧, អ៊ីម៉ែលៈ im.sophea@eccc.gov.kh